**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចព្រមព្រៀងរវាងនាយិកាក្រុមហ៊ុនសុខៈស្ប៉ានិងតំណាងកម្មករនិយោជិក ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី៦ ខែ ឧសភា ឆ្នាំ ២០២០វេលាម៉ោង ៩ និង ៣០នាទី នៅក្នុងក្រុមហ៊ុនសុខៈស្ប៉ាមានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះនាយិកាក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុនថា ដោយសារការរីករាលដាលនិងចម្លងនៃជំងឺរលាកសួតប្រភេទថ្មីCovid-19ដែលជាហេតុបណ្តាលអោយមានផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកហើយក៏ជាហេតុដែលធ្វើអោយក្រុមហ៊ុនទទួលរងការខាតបង់ មិនមានប្រាក់ចំណូលសំរាប់ទ្រទ្រង់ប្រតិបត្តិការណ៍បន្តទៀតបាន។

ហេតុដូចនេះក្រុមហ៊ុនបានសំរេចចិត្តធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិកទាំងអស់ ចំនួន៤៩នាក់(ស្រី៣១នាក់)រយៈពេល៥៧ថ្ងៃដោយគិតចាប់ពីថ្ងៃទី០៦ខែឧសភា ឆ្នាំ២០២០ រហូតដល់ទី០១ ខែកក្កដា ឆ្នាំ២០២០ នៅក្នុងកំឡុងពេលនៃការព្យួរនេះកម្មករនិយោជិកបានទទួលស្គាល់នូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួលចំនួន៦០ដុល្លារអាមេរិកក្នុងមួយខែសំរាប់កម្មករនិយោជិកម្នាក់ៗ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០និង៣០នាទីនាថ្ងៃខែឆ្នាំដដែល ដោយសារភាគីទាំងសងខាងមានការស្និទ្ធស្នាលនិងយោគយល់គ្នាក្រោមស្មារតីទទួលនិងសហការគ្នាយ៉ាងរលូន។

ថ្ងៃពុធ ១៥កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣
សៀមរាប ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០២០

ហត្ថលេខា និងត្រា នាយិកា




ជុនតាប់

តំណាងកម្មករនិយោជិក

